ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ.១៤.០២១.០០៥.ឈកាសព័ត៌មាន

ថ្ងៃ ព្រហស្បតិ៍ ៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
## ការចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាននិងចំណេះដឹងផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

នៅថ្ងៃព្រហស្បតិ៍ ៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០២១ ធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាននិងចំណេះដឹងផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃស្ថាប័នទាំងពីរ។

ការចុះអនុស្សរណៈយោគយល់នេះប្រព្រឹត្តទៅក្នុងគោលបំណងលើកកម្ពស់ការចែករំលែកព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងនវានុវត្តន៍ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យកាន់តែមានភាពងាយស្រួល និងប្រសិទ្ធភាព។ ស្របពេលជាមួយគ្នានេះ អនុស្សរណៈ-យោគយល់នេះជាសក្ខីភាពមួយដ៏សំខាន់ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ ក៏ដូចជាចូលរួមចំណែកក្នុងការជំរុញនវានុវត្តន៍ និងការប្រើប្រាស់សេវាធនាគារអេឡិចត្រូនិកប្រកបដោយ និរន្តរភាព ចីរភាព សុវត្ថិភាព និងបរិយាបន្ន ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចឌីជីថលស្រប តាមគោលដៅរបស់រដ្ឋាភិបាល។

លើសពីនេះ អនុស្សរណៈយោគយល់នេះក៏ជាផ្ទាលសម្រាប់ពង្រឹងសមត្ថភាព និងចំណេះដឹង ផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់មន្ត្រីពាក់ព័ន្ធរបស់ស្ថាប័នទាំងពីរដូចមានចែងក្នុងខ្លឹមសារនៃ អនុស្សរណៈយោគយល់ដើម្បីអនុវត្តការងារផ្សេងៗ ឱ្យកាន់តែមានប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការ និងការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន។